ទំព័រការពិត

អ្វីទៅដែលហៅថា ខ្សែយាន្តជំនិះកណ្តាល?

- ខ្សែយានជំនិះកណ្តាល គឺជាខ្សែយានជំនិះដែលមានចំងាយ ១១ម៉ាយ ភ្ជាប់ពីទីក្រុង មីនីអាប៉ូលិស ទៅមណ្ឌលក្រុងសេនប៉ូល និង សកលវិទ្យាល័យមីនីសូតា ដោយរួមទាំង តំបន់រស់នៅនានា និងចន្លោះតំបន់ពាណិជ្ជកម្ម។

តើការដឹកនាំប្រភេទណាដែលបានគ្រោង អំពីខ្សែយានជំនិះកណ្តាល?

- ដូចគ្នានឹងខ្សែរថភ្លើងខ្លីៗ ដែលក្នុងបច្ចុប្បន្ននេះ កំពុងរត់នៅផ្លូវហាយវ៉ាតា ក្នុងក្រុង មីនីអាប៉ូលីស។

តើខ្សែយានជំនិះកណ្តាលនេះមានអត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋមីនីសូតាតាមរបៀបណា?

- បុគ្គលិកនានា ធ្វើការនៅក្នុងតំបន់កណ្តាល និងតំបន់ហាយវ៉ាតា ដោយរួមទាំងចំណត យន្តហោះ ផ្សារធំអាមេរិកា សាកលវិទ្យាល័យមីនីសូតា និងផ្លូវមីដវេសេនប៉ូល។ ទាំងអស់នេះជាផ្លូវដែលអាចពឹងពាក់បាន ក្នុងការធ្វើដំណើរទៅកាន់ការងាររបស់ពួកគេ។
- ខ្សែរថភ្លើងខ្លីៗនេះ មានអ្នកដំណើរជិះវា ចំនួន ៥៣,០០០ នាក់នៅឆ្នាំ ២០៣០ ដោយ យោងទៅតាមការប្រមាណ នៅថ្ងៃធម្មតា។
- វាមានការស្ទះចរាចរណ៍តិចជាងមុន សំរាប់អ្នករស់នៅទីក្រុងទាំងពីរ និងភ្ញៀវ។
- ពាណិជ្ជកម្ម ឬហាងជំនួញនានា ដែលនៅតាមដងផ្លូវខ្សែរយានជំនិះកណ្តាល នឹងបាន ទទួលអត្ថប្រយោជន៍ ពីការមើលឃើញ និងការអភិវឌ្ឍន្នដែលនឹងកើតឡើង តាមការ ប្រសើរឡើងនានានៃការធ្វើដំណើរ។
- ការធ្វើដំណើរឆ្លងកាត់ដោយនាំមនុស្សច្រើន ធ្វើការកាត់បន្ថយជាតិឧស្ម័ន ហើយធ្វើ អោយគុណភាពខ្យល់អាកាសប្រសើរឡើងទៀតផង។

តើហេតុអ្វីបានជាត្រូវការភាពផ្លាស់ប្តូរ អំពីខ្សែយានជំនិះកណ្តាល?

- មានការជឿជាក់ថា ចរាចរនឹងកើនឡើង ៥៨ភាគរយ នៅឆ្នាំ២០២០ ដែលធ្វើអោយ មានភាពស្ទះយ៉ាងខ្លាំង។
- ដោយព្រោះតែផ្លូវធំលេខ ៩៤ គឺជាផ្លូវមានកំរិតក្នុងការពង្រីក ហើយប្រមើលថា នឹង ហួសចំណុះត្រឹមឆ្នាំ២០២០ ដូច្នេះក្នុងការពង្រីកចំណុះ វានឹងអស់សាហុយលើស ជាង ១០០០ លានសហរដ្ឋអាមេរិក ក៏បង្ខិតបង្ខោចសង្កាត់ភូមិនានា ព្រមទាំងពន្ធ ការស្ទះចរាចរដែលមិនអាចចៀសរួចនោះ អោយយូរអន្លាយទៀតផង។
- សង្កាត់ពាណិជ្ជកម្មនៅតំបន់ មីដវេ ជាតំបន់មួយក្នុងចំណោមតំបន់លូតលាស់ខ្លាំង បំផុត និងតំបន់រស់នៅទាំងអស់ ដែលនៅក្នុងទីក្រុងមីនីអាប៉ូលីស សេនប៉ូល ហើយក៏ជាកន្លែងដែលមានការស្ទះបំផុតដែរ។ ការអោយមានភាពប្រសើរក្នុងការដឹក ជញ្ជូន នឹងអោយមានការទ្រទ្រង់នៃការលូតលាស់។
- តំបន់នៅ មហាវិថី យូនីវើស៊ីធី មានសក្តានុពល នឹងក្លាយទៅជាតំបន់អភិវឌ្ឍន្នមួយ ក្នុងចំណោមតំបន់ទាំងអស់ នៅក្រុងមីនីអាប៉ូលីស សេនប៉ូល។

តើខ្សែយានដ្ឋជំនិះកណ្តាលមានតួនាទីអ្វី ទៅលើប្រព័ន្ធដឹកជញ្ជូនតំបន់?

- ការដឹកជញ្ជូន មានអត្ថប្រយោជន៍ល្អបំផុត នៅពេលដែលវាភ្ជាប់គោលដៅ សំខាន់ទាំងឡាយជាមួយគ្នា ហើយនិងបំរើសេវាពិសេស។ ជាមួយនិងខ្សែរផ្លូវ ហាយវ៉ាតា ទង្វើប្រសើរនៃខ្សែយានជំនិះកណ្តាល នឹងផ្សារភ្ជាប់នូវសេដ្ឋកិច្ចធំៗ ទាំងអស់ និងទិសដៅនៃភូមិតំបន់រស់នៅទាំងអស់ នៅក្នុងក្រុងមីនីអាប៉ូលិស សេនប៉ូល និងផ្តល់ការដឹកជញ្ជូន នៅជុំវិញតំបន់រស់នៅនានា។

តើនឹងមានការចំណាយប៉ុន្មានទៅលើខ្សែយានដ្ឋជំនិះកណ្តាល?

- ការចំណាយទៅលើខ្សែរថភ្លើងខ្លីៗ នៃខ្សែយានជំនិះកណ្តាល គឺ ៩៣០ លាន ដុល្លារសហរដ្ឋអាមេរិក។

សំរាប់ពណ៍មានបន្ថែម សូមទំនាក់ទំនងមក :

លោក Steve Morris, ចៅហ្វាយគំរោងការធ្វើដំណើរឆ្លងកាត់
អាស័យដ្ឋាន Ramsey County Regional Railroad Authority
Suite 6560, RCGC-West, 50 West Kellogg Blvd.
St. Paul, MN 55102 ទូរស័ព្ទលេខ 651-266-2784